00165936

C11/49

**អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០១) |
| បញ្ជូនទៅ៖ | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទនៃឯកសារ៖ | ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨ |
| ភាគីបញ្ជូន៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម៖ | ភាសាអង់គ្លេស |
| ប្រភេទឯកសារ៖ | ជាសាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 03 / 2008
ម៉ោង (Time/Heure): 15h00 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណារួមគ្នារបស់មេធាវីការពារក្តី ស្តីពី ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការសម្រេចឃុំខ្លួនបណ្តោះអាសន្ន

**បញ្ជូនដោយ៖**

**ការិ. សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក តាន់ សេណារ៉ុង
លោក Anees AHMED

**បញ្ជូនទៅ៖**

**អង្គបុរេជំនុំជម្រះ៖**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ នួន ជា៖**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor KOPPE

**មេធាវីការពារក្តីរបស់ ដើមបណ្តឹងរដ្ឋប្បវេណី៖**
លោក ហុង គឹមសួន
លោក ឡោ ជុនធី
លោក នី ចាន់ឌី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 06 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

## ១. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញា ឆ្លើយតប[1] ទៅនឹងកន្លែង សេចក្តីសំអាង ក ក្នុងការដាក់ជូនសារណារួមគ្នារបស់មេធាវីការពារក្តី ស្តីពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន[2] ។ ចំពោះផ្នែកដែលនៅសេសសល់នៃរឿងវិវាទនៅក្នុងសារណារបស់មេធាវីការពារក្តី សហព្រះរាជអាជ្ញា សូមបញ្ជាក់ដដែលឡើងវិញម្តងទៀត និងសូមដាក់បញ្ចូលដោយយោងទៅលើសេចក្តីសំអាងទាំងឡាយ ដែលបានលើកឡើងនៅក្នុងសារណារបស់ពួកគេដែលបានដាក់ជូនកាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨[3] ។

២. ដោយលើកមកសំអាងនូវលិខិតទទួលស្គាល់(“លិខិតទទួលស្គាល់”)ដែលចេញដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត (“ស.ច.ស”)[4] មេធាវីការពារក្តីជំទាស់ថា អង្គបុរេជំនុំជម្រះ (“អ.ប.ជ”) “មិនមានយុត្តាធិការ”ក្នុងការអនុញ្ញាតឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីនានាចូលរួមនៅក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់ចំពោះការឃុំខ្លួនបណ្តោះអាសន្នបានទេ លុះត្រាតែ

---

[1] *ករណីរបស់ នួន ជា* សេចក្តីជូនដំណឹងស្តីពីការដាក់សារណាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងការអញ្ជើញអ្នកដែលមិនមែនជាភាគី សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០១) ចុះថ្ងៃទី១២ កុម្ភៈ ២០០៧ ERN 00162546-00162548, C11/36, ទំព័រទី ៣ (អនុញ្ញាតពេលរហូតដល់ថ្ងៃទី០៦ ខែមីនា ដើម្បីឲ្យសហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងការដាក់ជូនដែលបានធ្វើឡើងដោយភាគីនានា ឬ ដោយមិត្តរបស់តុលាការ) ។

[2] *ករណីរបស់ នួន ជា* សារណារួមគ្នាស្តីពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ០១) ចុះថ្ងៃទី២២ កុម្ភៈ ២០០៧ ERN 00164866-00164877, C11/45, កថាខណ្ឌទី ១៩, ២០ [*ដែលតមកទៀតនៅក្នុងនេះហៅថា* សារណារបស់មេធាវី] ។

[3] *ករណីរបស់ នួន ជា* ការដាក់ជូនរបស់សហព្រះរាជអាជ្ញា ស្តីពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០១) ចុះថ្ងៃទី ២២ កុម្ភៈ ២០០៧ ERN 00164711-001648720, C11/44 ។

[4] សារណារួមគ្នារបស់មេធាវីការពារក្តី កំណត់សម្គាល់ជើងទំព័រលេខ ៣២ [*ដែលតមកទៀតនៅក្នុងនេះហៅថា* លិខិតទទួលស្គាល់] ។

00165938



"សហចៅក្រមស៊ើបអង្កេតខ្លួនឯងផ្ទាល់" បានពិនិត្យឡើងវិញនិងបានយល់ព្រមនៅលើពាក្យសុំរបស់ភាគីទាំងនោះហើយសិន[5] ។

## ២. សេចក្តីសន្និដ្ឋាន

៣. សហព្រះរាជអាជ្ញា សូមស្នើដាក់ជូនថា ការជំទាស់របស់មេធាវីការពារក្តីនេះមិនស្របទៅនឹងយន្តការក្នុងការទទួលស្គាល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលបានចែងក្នុងវិធានផ្ទៃក្នុង("វិធាន")[6] និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះទេ ("សេចក្តីណែនាំអនុវត្ត")[7] ។

*ចំណាត់ការរបស់ក្រឡាបញ្ជីគឺមានសុពលភាព: មិនចាំបាច់តម្រូវឱ្យមានដីកាសំអាងហេតុរបស់ ស.ច.ស ទេ*

៤. អនុលោមតាមវិធាន ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយ អាចដាក់ពាក្យសុំទៅ ស.ច.ស ដើម្បីស្នើចូលរួមក្នុងនាមជាភាគីនៅក្នុងដំណើរការនីតិវិធីបាន[8] ។ ក៏ប៉ុន្តែ ការណ៍នេះតម្រូវឱ្យ ស.ច.ស ចេញដីកាសំអាងហេតុនៅក្នុងករណីដែលមិនទទួលយល់ព្រមនៅលើពាក្យសុំ*តែប៉ុណ្ណោះ* ។ នៅក្នុងសេចក្តីណែនាំអនុវត្តន៍ក៏បានរំលេចឱ្យឃើញពីការអនុវត្តន៍នេះដែរ និងតម្រូវឱ្យ ស.ច.ស ចេញជាសេចក្តីសម្រេចមួយតែនៅពេលណា "បើសិនជាអាចអនុវត្តទៅបាន"[9] តែប៉ុណ្ណោះ ។ ទាំងនៅក្នុងវិធាន ឬទាំងនៅក្នុងសេចក្តីណែនាំអនុវត្តក្តី សុទ្ធតែមិនមានចែងពី ស.ច.ស ត្រូវចេញដីកាសំអាងហេតុនៅពេលបានទទួលយល់ព្រមលើពាក្យសុំ

---

[5] សារណារួមគ្នារបស់មេធាវីការពារក្តី កថាខណ្ឌទី ១៩, ២០ ។

[6] វិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក វិសោធនកម្មលើកទី១ ថ្ងៃទី០១ កុម្ភៈ ២០០៨ [*ដែលតមកទៀតនៅក្នុងនេះហៅថា* វិធានផ្ទៃក្នុង] ។

[7] សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ សេចក្តីណែនាំអនុវត្តលេខ ០២/២០០៧ ចុះថ្ងៃទី០៥ តុលា ២០០៧ [*ដែលតមកទៀតនៅក្នុងនេះហៅថា* សេចក្តីណែនាំអនុវត្ត] ។

[8] វិធានផ្ទៃក្នុង វិធាន ២៣.៣ ។

[9] សេចក្តីណែនាំអនុវត្ត មាត្រា ៣.១០ ។

តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេ ។ ផ្អែកតាមនេះ ស.ច.ស ត្រូវគិតទុកជាមុនអំពីការធ្វើបណ្តឹងឧទ្ធរណ៍ តែនៅពេលជំទាស់នឹងដីកាដែលបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ (ដែលតម្រូវឲ្យចេញដីកាសំអាងហេតុ) ហើយមិនជំទាស់នឹងដីកាដែលទទួលយល់ព្រមឲ្យតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ (ប្រការនេះមិនតម្រូវឲ្យចេញដីកាសំអាងហេតុទេ)[10] ។

៥. ផ្អែកតាមសាវតារឿងនេះ ក្រឡាបញ្ជីនៃ ក.ស.ច.ស បានអនុវត្តដោយត្រឹមត្រូវក្នុងការចេញលិខិតទទួលស្គាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ គឺវិធានផ្ទៃក្នុងអនុញ្ញាតឲ្យពួកគេអនុវត្តដូច្នេះ[11] ។ លើសពីនេះ ក្នុងលិខិតទទួលស្គាល់ទាំងនេះបានសរសេរថា ពាក្យសុំរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានវិភាគ "ដោយ ស.ច.ស" គឺជាការបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ស.ច.ស បានធ្វើការពិនិត្យពិច័យយ៉ាងត្រឹមត្រូវលើពាក្យសុំទាំងនេះ ដើម្បីឲ្យបានសមស្រប ហើយមិនបានទទួលយល់ព្រមដែលធ្វើដោយគ្មានការពិចារណានោះទេ[12] ។ ប៉ុន្តែក្រឡាបញ្ជី[13] បានជូនដំណឹងដល់អ្នកដាក់ពាក្យសុំទាំងនោះថា នៅពេលណាក៏បានក្នុងអម្លុងពេលនៃការស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាច"បដិសេធ"ពាក្យសុំរបស់ពួកគេបាន បើសិនជាពួកគេមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យ សម្រាប់ការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណាក់កាលនោះ[14]។

៦. យន្តការនេះមានភាពស៊ីសង្វាក់គ្នាទៅនឹងការអនុវត្តន៍ និងនីតិវិធីនៃតុលាការដែលជំរុញឲ្យមានការអនុវត្តន៍ច្បាប់តាមប្រព័ន្ធច្បាប់ស៊ីវិលដូចជា អ.វ.ត.ក នេះជាដើមដែល ស.ច.ស នៅពេល

---

[10] វិធានផ្ទៃក្នុង វិធាន ២៣.៣ ។ សេចក្តីណែនាំអនុវត្ត មាត្រា ៣.៩ ។

[11] វិធានផ្ទៃក្នុង វិធាន១៤.២ (ដែលចែងថា ក្រឡាបញ្ជីត្រូវរក្សាឯកសារស៊ើបសួរ និងបំពេញសកម្មភាពដទៃទៀតតាមតម្រូវការរបស់ ស.ច.ស ។

[12] *សូមអានករណីរបស់ ទួន ជា* អំពីឋានៈនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ ក.ស.ច.ស ចុះថ្ងៃទី២៧ ធ្នូ ២០០៧ ERN 00157040-00157041, D22/6/2 កថាខណ្ឌទី ១ ។

[13] សូមអានសេចក្តីណែនាំអនុវត្ត មាត្រា ៣.៨ ។

[14] *សូមអានករណីរបស់ ទួន ជា* អំពីឋានៈនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី២៧ ធ្នូ ២០០៧ ERN 00157040-00157041, D22/6/2 កថាខណ្ឌទី ៣ ។

00165940



ណាមួយរហូតដល់ពេលចេញដីកាដំណោះស្រាយ អាចធ្វើការសន្និដ្ឋានថា ពួកគេលែងត្រូវការតទៅទៀតហើយ ក្នុងការរក្សាទុកភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានកំណត់ រួចហើយព្រោះដោយសារមានការលេចឡើងនូវអង្គហេតុថ្មីៗ ឬការកំណត់បទចោទប្រកាន់ ដែលបានចោទទៅលើពួកគេ ។ ដីកាមិនទទួលយល់ព្រមនឹងនាំមកនូវផលវិបាកខាងផ្លូវច្បាប់ផ្ទុយគ្នាសំរាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ហើយតាមការកំណត់នេះតុលាការទាំងនោះបើកឲ្យធ្វើបណ្តឹងឧបាស្រ័យចំពោះភាគីនោះ ក្នុងការប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាបង្គាប់នោះ[15] ។

៧. យន្តការនេះក៏បានធ្វើយុត្តិកម្មអំពីហេតុផលខាងនយោបាយផងដែរ ។ ស.ច.ស មិនត្រូវបានតម្រូវឲ្យចេញដីកាសំអាងហេតុទេ នៅពេលទទួលឲ្យមានជាភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយព្រោះថាការធ្វើដូចនេះ ស.ច.ស ត្រូវធ្វើការសម្រេច-ទោះបីជាតាមទិដ្ឋភាពខាងក្រៅដោយសន្មត(*ដែលឃើញមួយក្រឡេកភ្នែក*)-ថាតើអ្នកដាក់ពាក្យសុំនោះគឺជា *ជនរងគ្រោះ* ដោយសារ *ឧក្រិដ្ឋកម្ម* មែនឬក៏មិនមែន-ហេតុដូច្នេះហើយ នៅមុនពេលបញ្ចប់កិច្ចស៊ើបសួរ ត្រូវធ្វើសេចក្តីសន្និដ្ឋានមួយដោយមិននិយាយឲ្យចំៗថា ឧក្រិដ្ឋកម្មបានកើតឡើងទេ ។ អាស្រ័យហេតុនេះការអនុវត្តន៍ដែលមិនតម្រូវឲ្យចេញដីកាសំអាងហេតុ គឺរក្សាបាននូវលក្ខណៈដែលស្របនឹងការពិត និងអព្យាក្រឹតភាពនៅក្នុងការស៊ើបសួរ ព្រមទាំងផ្តល់ឲ្យមានសច្ចធារណ៍នៃនិរទោសដល់ជនត្រូវចោទ[16] ។

៨. ក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ក៏ចែងយ៉ាងច្បាស់លាស់ពីបញ្ហានេះដែរ ។ ក្នុងក្រមនេះបានចែងថា នៅពេលបានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហើយនោះ *ពាក្យសុំនោះត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង* (ដោយភ្ជាប់ជាមួយនឹងសំណុំរឿង)[17] ។ ចៅក្រមមាន

---

[15] វិធានផ្ទៃក្នុង, វិធាន ២៣.៣ ។

[16] ការពោលអះអាងថា អ្នកដាក់ពាក្យសុំគឺជាជនរងគ្រោះមួយរូបនោះ ក៏ត្រូវបានលើកបញ្ជាក់ផងដែរក្នុងន័យថាបទល្មើសព្រហ្មទណ្ឌមួយបានកើតឡើង ។

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១៣៧ ។

កាតព្វកិច្ចក្នុងការជូនដំណឹងដល់ភាគីនានាតែប៉ុណ្ណោះ[18] ។ ការអនុវត្តន៍នេះ គឺស្រដៀងគ្នានៅក្នុងយុត្តាធិការនានាដែលប្រើប្រព័ន្ធច្បាប់ស៊ីវិល[19] ។

*ជាជំនួស គឺ "ស.ច.ស ខ្លួនឯងផ្ទាល់" បានទទួលស្គាល់ ភាគីដើមបណ្តឹងរដ្ឋប្បវេណី*

៩. ឯកសារនៅក្នុងសំណុំរឿងបង្ហាញឲ្យឃើញថា នៅពេលចាំបាច់ សហចៅក្រមស៊ើបអង្កេត "ខ្លួនឯងផ្ទាល់"បានចេញដីកាស្តីពីការចូលរួមនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ ឧទាហរណ៍ដូចជា ស.ច.ស ចេញដីកាដូចនេះ នៅក្នុងពេលទទួលស្គាល់មេធាវីការពារក្តីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន២៣[20] ។ ស្រដៀងគ្នានេះដែរ ស.ច.ស បានសន្និដ្ឋានថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬបណ្តឹងរបស់ជនរងគ្រោះណាមួយដែលមានលក្ខណៈមិនគ្រប់គ្រាន់ ដាក់ជូនមកដោយមិនត្រឹមត្រូវ មិនមានការជាប់ទាក់ទងទៅនឹងបទល្មើសទាំងឡាយដែលកំពុងស្ថិតក្នុងការស៊ើបសួរ ឬជាបទល្មើសព្រហ្មទណ្ឌដែលស្ថិតនៅក្រៅពីក្នុងយុត្តាធិការរបស់តុលាការ ស.ច.ស បានសម្រេចយ៉ាងដូច្នេះតាមរយៈដីកាមួយដ៏សមស្រប[21] ។ នៅទីបញ្ចប់ហើយដែលសំខាន់ជាងគេបំផុតនោះគឺ ស.ច.ស នៅក្នុងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់ខ្លួន ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ បានធ្វើការកត់សំគាល់យ៉ាងច្បាស់ថា ស.ច.ស "បានទទួល" ពាក្យសុំពីជនរងគ្រោះនានា និង "បានយល់ព្រមផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដល់មនុស្សចំនួន ៤ នាក់"[22] ។

---

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា១៣៧ ។

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ អត្ថបទចុះថ្ងៃទី០៥ មករា ២០០៨ ចូលជាធរមានចាប់ពីថ្ងៃទី២០ កុម្ភៈ ២០០៨ អាចរកមើលបាននៅក្នុង www.legifrance.gouv.fr [*ដែលតមកទៀតនៅក្នុងនេះហៅថា* ក្រមនីតិវិធីព្រហ្មទណ្ឌ នៃប្រទេសបារាំង] ។

[20] *សូមអានជាឧទាហរណ៍ ករណីរបស់ នួន ជា* សេចក្តីសម្រេចទទួលស្គាល់មេធាវី សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី៣១ មករា ២០០៨ ERN 00160732-00160733, D22/7/5 ។

[21] *សូមអានជាឧទាហរណ៍ ករណីរបស់ នួន ជា* ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី២៧ ធ្នូ ២០០៧ ERN 00156515-00156516 ។

[22] *សូមអាន ករណីរបស់ នួន ជា* ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី២៩ កុម្ភៈ ២០០៧ ERN 00165199-00165200, D77 ទំព័រទី ១ ។

00165942



E11/45

១០. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យ អង្គបុរេជំនុំជម្រះបដិសេធចោលនូវសារណារួមរបស់មេធាវីដែលបានដាក់ជូនថា "មិនអាចទទួលយកបាននូវនីតិវិធី" របស់ ស.ច.ស បានទេដោយមកពី "ស.ច.ស ផ្ទាល់" មិនបានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទេ[23] ។

*ការទទួលស្គាល់ មិនត្រូវបានជំទាស់នៅចំពោះមុខ ស.ច.ស ឡើយ:*
*ការជំទាស់នៅចំពោះមុខ អ.ប.ជ គឺមិនអាចអនុញ្ញាតឲ្យបានទេ*

១១. នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស.ច.ស បានទទួលស្គាល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយដែលបានចូលបង្ហាញខ្លួននៅចំពោះមុខ អ.ប.ជ នៅក្នុងកំឡុងពេលនៃសវនាការលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្ដោះអាសន្ន[24] ។ រហូតមកដល់ពេលនេះ មេធាវីការពារក្ដីមិនបានធ្វើការតវ៉ាចំពោះការទទួលស្គាល់ពួកគេដោយ ស.ច.ស នេះឡើយ[25]។ សហព្រះរាជអាជ្ញាសូមស្នើដាក់ជូនថា ឥឡូវនេះវិធាននានាបានរាំងដល់មេធាវីការពារក្ដី មិនឲ្យធ្វើការតវ៉ាជំទាស់អំពីការទទួលស្គាល់នេះក្នុងពេលប្ដឹងឧទ្ធរណ៍ទេ ។ នៅក្នុងវិធាន ឬ ទាំងនៅក្នុងសេចក្ដីណែនាំអនុវត្ត គឺសុទ្ធតែមិនបានប្រគល់អំណាចទៅឲ្យ អ.ប.ជ ដើម្បីទទួលស្គាល់ ឬ មិនទទួលស្គាល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ។ អំណាចនេះគឺប្រគល់ទៅឲ្យតែ ស.ច.ស ឬ អង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ ទៅតាមការចាំបាច់[26] ។

## ៣. សំណើ

១២. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យ អ.ប.ជ ៖

---

[23] សារណារួមគ្នារបស់មេធាវីការពារក្ដី កថាខណ្ឌទី ១៩, ២០ ។

[24] សារណារួមគ្នារបស់មេធាវីការពារក្ដី កំណត់សំគាល់ជើងទំព័រ លេខ ៣២ ។

[25] *សូមមើលជាឧទ្ធរណ៍ ករណីរបស់ នួន ជា* អំពីចាត់ៈពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី២០ វិច្ឆិកា ២០០៧ ERN 00152966 ។

[26] វិធានផ្ទៃក្នុង វិធាន ២៣.៣, ២៣.៤ ។ សេចក្ដីណែនាំអនុវត្ត មាត្រា ៣.៣ ។

i. បដិសេធចោលនូវ សេចក្តីសំអាង ក ដែលបានលើកឡើងនៅក្នុងសារណារួមរបស់មេធាវីការពារក្តីដែលបានដាក់ជូន ។ និង

ii. ពិចារណាទៅលើខ្លឹមសារ ដែលនៅសេសសល់ទាំងអស់នៃសារណារួមរបស់មេធាវីការពារក្តីដែលបានដាក់ជូន ដោយផ្អែកលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ ។

សូមដាក់ជូនដោយសេចក្តីគោរពអំពីយើងខ្ញុំ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨
**សហព្រះរាជអាជ្ញា**

**លោក យ៉េត ចរិយា**
សហព្រះរាជអាជ្ញារង

**លោក** Robert PETIT
សហព្រះរាជអាជ្ញា